San Diego City Schools

លិខិតពត៌មាន រដូវស្លឹកឈើធ្លាក់ឆ្នាំ ២០០៤

# កម្មវិធីយាមល្បាតរបស់ក្រសួងប៉ូលីសប្រចាំទីក្រុង សាន់ឌីអេហ្គោ

សន្តិសុខរបស់សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ មានសារៈសំខាន់ជាងគេបង្អស់នៅក្នុងក្រសួងអប់រំប្រចាំក្រុង។ ការបំរើរបស់ក្រសួងប៉ូលីសរៀបចំកម្មវិធីការពារយ៉ាងប្រុងប្រយ័ត្ននូវគោលជំហរសហគមន៍អំពី កម្មវិធីការពារអំពើឧក្រិដ្ឋ ដើម្បីបន្ថយបញ្ហា ចោរលបចូលលួចទ្រព្យសម្បត្តិ, ការគូសបំផ្លាញនៅតាមជញ្ជាំងសាធារណៈ, ការបំផ្លាញទ្រព្យសម្បត្តិ, ការលួច, ព្រមទាំងការលួចដុតបំផ្លាញ ហេតុដូច្នោះកម្មវិធីយាមល្បាតនេះធ្វើឡើងសំរាប់សាលាលារៀនទាំងអស់។ កម្មវិធីយាមល្បាតរបស់សាលារៀនលើកទឹកចិត្តសហគមន៍, ចាស់ទុំទូទៅ, សិស្ស និងហាងជំនួញដែលជាដៃគូជួយធ្វើការយាមល្បាតនូវហេតុផលគ្រប់បែបយ៉ាង ឬមានការសង្ស័យ ពេលសាលារៀនបើកទ្វាបំរើសិស្ស, ក្រោយពេលសិស្សចេញទៅផ្ទះ ឬពេលសាលារៀនបិតទ្វាក្តី។

ក្រសួងអប់រំប្រចាំក្រុងចំណាយថវិការជារៀងរាល់ឆ្នាំចំនួនជាង មួយលានដុល្លារ ។ យើងមានកម្មវិធីស្នាក់បំរើយាមល្បាតដល់សាលារៀនអាចជួយកាត់បន្ថយការចំណាយនេះបានមួយចំនួន។ ដោយមានការព្យាយាមប្រឹងប្រែងពីសហគមន៍សាលារៀន ពួកគេអាចជួយធ្វើអោយសាលារៀនមានសន្តិសុខ ព្រមទាំងជួយការពារអំពើឧក្រិដ្ឋកម្មផងដែរ។

ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៤ ក្រសួងប៉ូលីសប្រចាំក្រសួងអប់រំចាប់ផ្តើមកម្មវិធីយាមល្បាតនៅតាមសាលាវិទ្យាល័យ Serra ។ ការធ្វើនេះរៀបចំឡើងដើម្បីអោយប្រជាជនដែលរស់នៅក្បែរតំបន់សាលារៀនធ្វើជាភ្នែក និងត្រចៀកដែលអាចជួយការពារដល់សាលារៀនយើងបាន។ កម្មវិធីនេះគឺចាប់ផ្តើមប្រតិបត្តិនៅតាមសហគមន៍សាលាវិទ្យាល័យ Serra ។

នារដូវស្លឹកឈើធ្លាក់នេះ ភ្នាក់ងារប៉ូលីសប្រចាំ SDCS នឹងដើរគោះទ្វាតាមផ្ទះនិមួយៗដើម្បីពន្យល់ប្រជាជនអោយបានជ្រាបអំពី កម្មវិធីស្នាក់បំរើដ៏ថ្មីនេះ។ គេស្នើសុំអោយប្រជាជនធ្វើការកែប្រែកាលវិភាគបើកទឹកស្រោចស្មៅ, លាងឡាន, ការរត់ហាត់ប្រាណ។ល។ ម្ល៉ោះហើយពួកគាត់អាចជួយយាមល្បាតមើលនូវអំពើឧក្រិដ្ឋកម្ម ពេល ឬក្រោយពេលសាលារៀនបិតទ្វាបាន។

បើមានការសង្ស័យអ្វីមួយមានរួមដូចជា ឃើញបុគ្គលណាម្នាក់ដើរត្រែតត្រតនៅក្បែរសាលារៀន, ឮសំឡេងខ្លាំងៗដូចជា: បែកកញ្ចក់បង្អួចទូទៅ, វាយតប់គ្នា/សម្រែកឮខ្លាំងៗ, ឃើញបុគ្គលទាំងនោះរត់ចេញពីសាលារៀន, គូសបំផ្លាញលើជញ្ជាំងសាលារៀន, លោតតោងលេងនឹងរង្វង់កន្ត្រកសំណាញ់បាសស្កេតបាល់, ធ្វើអោយបាក់បែកផ្លាកសាលារៀន, បំផ្លាញដល់សួនដំណាំសាលារៀន។ល។

បើមានឃើញហេតុផលសង្ស័យអ្វីមួយ ប្រជាជនដែលជួយរាយការណ៍អំពី ហេតុផលទាំងនេះដោយមិនចាំបាច់ប្រាប់ឈ្មោះរបស់ខ្លួនឡើយ។ សេចក្តីរាយការណ៍ទាំងអស់នឹងរក្សាដោយសម្ងាត់ ហើយលេខទូរស័ព្ទរបស់គាត់ដែលគេបានឃើញនឹងមិនចែកចាយទៅបុគ្គលណាជាដាច់ខាត។

## សង្ខេប

- យល់ព្រមជួយការពារសាលារៀនដែលនៅក្បែរតំបន់របស់ខ្លួនរស់នៅ។
- ជាភ្នែក និងត្រចៀកដើម្បីជួយដល់សាលារៀន
- ក្រសួងអប់រំចំណាយថវិការជារៀងរាល់ឆ្នាំចំនួនជាង ១លានដុល្លារ ទៅលើការខូតខាតរបស់សាលារៀនទាំងអស់។
- ការជួយយាមល្បាតដល់សាលារៀនមានដូចតទៅ:
  - ឃើញបុគ្គលណាម្នាក់ដើរត្រែតត្រតនៅក្បែរសាលារៀន។
  - ឮសំឡេងខ្លាំងៗដូចជា: បែកកញ្ចក់បង្អួចទូទៅ, វាយតប់គ្នា, សម្រែកឮខ្លាំងៗ។
  - ឮសំឡេងរត់ចេញពីសាលារៀន, ពិសេសបើឃើញបុគ្គលទាំងនោះមានកាន់របស់របរជាប់នឹងខ្លួន។
  - គូសបំផ្លាញលើជញ្ជាំងសាលារៀន
  - លោតតោងលេងនឹងរង្វង់កន្ត្រកសំណាញ់បាសស្កេតបាល់
  - ធ្វើអោយបាក់បែកផ្លាកសាលារៀន
  - បំផ្លាញដល់សួនដំណាំសាលារៀន
- ការទូរស័ព្ទរាយការណ៍របស់លោកអ្នកទាំងអស់នឹងរក្សាដោយសម្ងាត់។
- ចូរទូរស័ព្ទមកលេខ (៦១៩) ២៩១-៧៦៧៨ ដើម្បីរាយការណ៍អំពី ភាពសង្ស័យអ្វីមួយ។

បើឃើញមានការសង្ស័យអ្វីមួយ ចូរទូរស័ព្ទមកក្រសួងប៉ូលីសប្រចាំសាលារៀនដែលមានលេខ **(៦១៩) ២៩១-៧៦៧៨។**

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងពត៌មាន: ក្រសួងប៉ូលីស SDCS (៦១៩) ៧២៥-៧២០០ ផ្នែកគ្រប់គ្រង (៦១៩) ២៩១-៧៦៧៨ ផ្នែកទាក់ទងតាមទូរស័ព្ទ
ការគម្រូតាមសាធារណៈ: (៦១៩) ៧២៥-៥៥៧៧ www.sandi.net

ការបំរើសិស្សជាង ១៣៨០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០០ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៨៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្ត្រ។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "

San Diego City School Police School Watch Program. Cambodian.